ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
មន្ទីរឧស្សាហកម្មនិងសិប្បកម្ម
ខេត្តព្រៃវែង

លេខៈ ៣២៨/១៦ ឧស.ព

# របាយការណ៍

# បូកសរុបសកម្មភាពអនុវត្ត
# ការងារប្រចាំឆ្នាំ ២០១៦
# និងទិសដៅឆ្នាំ ២០១៧

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
មន្ទីរឧស្សាហកម្ម និងសិប្បកម្ម
ខេត្តព្រៃវែង
លេខ:៧៧៤/១៦ឧស.ពវ

**គោរពជូន**
**ឯកឧត្តមទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**កម្មវត្ថុ** ៖ សូមជូនរបាយការណ៍បូកសរុបសកម្មភាពអនុវត្តការងារប្រចាំឆ្នាំ ២០១៦ និងទិសដៅអនុវត្តឆ្នាំ ២០១៧

សេចក្តីដូចបានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទមានកិត្តិយសសូមជំរាបជូនឯកឧត្តម ទេសរដ្ឋមន្ត្រី មេត្តាជ្រាបថា មន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តយើងខ្ញុំ បានអនុវត្តនូវសកម្មភាពការងារក្នុងរយៈពេល ១២ខែ ឆ្នាំ ២០១៦ទទួលបានលទ្ធផលដូចខាងក្រោមនេះ ៖

**I- សកម្មភាព និង លទ្ធផលការងារ**

**១-វិស័យឧស្សាហកម្មតូច-សិប្បកម្ម**

- ស្ថានភាពនិងស្ថិតិឧស្សាហកម្មតូចនិងមធ្យមសរុបចំនួន ៤០ មូលដ្ឋានក្នុងនោះសហគ្រិនជាស្ត្រីចំនួន ០២នាក់, ពលកម្មសរុប ២.៥៣៦ នាក់,ទុនអចល័តចំនួន២,៨៩២,៧៦៥ដុល្លារសរុបទាំងទុនចល័តចំនួន ៣,៨៣៣,២៧៤ដុល្លារ និងតម្លៃបរិមាណផលិតផលសរុបចំនួន ៧៤,៧២៦ លានរៀល ។
- ស្ថានភាព និង ស្ថិតិឧស្សាហកម្ម-សិប្បកម្មសរុបចំនួន ៣.៣៤៨ មូលដ្ឋាន ក្នុងនោះសហគ្រិនជាស្ត្រីចំនួន: ៩៩៣នាក់, ពលកម្មសរុបចំនួន: ៦.៩០៩នាក់, ទុនអចល័តសរុបចំនួន: ៣.៩៩៧.១៦០ដុល្លារ សរុបទាំងទុនចល័តចំនួន ៤.១៧៤.៣៣៩ដុល្លារ និងតម្លៃបរិមាណផលិតផលសរុប ២៤,៣៨៧ លានរៀល ។
- ឧស្សាហកម្មតូច-មធ្យម ដែលបានសុំប្រកាស និងអនុញ្ញាតដំណើរការពីក្រសួងសរុបចំនួន ៤០ មូលដ្ឋាន និងសិប្បកម្មចំនួន ២១ មូលដ្ឋាន សរុបចំនួន ៦១ មូលដ្ឋាន ។
- មូលដ្ឋានសិប្បកម្មកំពុងអនុញ្ញាតដំណើរការមានច្បាប់នៅមន្ទីរសរុបចំនួន ៣៨៦ មូលដ្ឋាន។
- មូលដ្ឋានឧស្សាហកម្មតូច-មធ្យមនិងសិប្បកម្មកំពុងដំណើរការមានច្បាប់សរុបចំនួន ៨៤៧ មូលដ្ឋាន។

* ការងារអនុវត្តបានក្នុងមួយឆ្នាំ:

- រៀបចំធ្វើសំណុំបែបបទសុំប្រកាសទឹកកកដើមនៅក្រសួងចំនួន ០៣ មូលដ្ឋាន។
- ធ្វើសំណុំបែបបទសុំប្រកាសទឹកសុទ្ធនៅក្រសួងចំនួន ០៣ មូលដ្ឋាន ។
- រៀបចំសំណុំបែបបទសុំប្រកាសសិប្បកម្មសិប្បកម្មលាយជី ជីកសិកម្មនៅក្រសួងចំនួន ០១ មូលដ្ឋាន ។
- សុំវិញ្ញាបនបត្រដំណើរការបន្តម៉ាស៊ីនកិនស្រូវនៅក្រសួងចំនួន ០២ មូលដ្ឋាន ។
- ចុះបញ្ជី និងវិញ្ញាបនបត្របន្តទឹកសុទ្ធនៅក្រសួងចំនួន ០១ មូលដ្ឋាន ។
- សុំវិញ្ញាបនបត្រដំណើរការបន្តឡឥដ្ឋនៅក្រសួងចំនួន ០១ មូលដ្ឋាន ។
- វិញ្ញាបនបត្របន្តដំណើរការឡឥដ្ឋនៅមន្ទីរចំនួន ០៦ មូលដ្ឋាន ។
- សុំវិញ្ញាបនបត្របន្តដំណើរការទឹកពិសាដបនៅមន្ទីរចំនួន ០២ មូលដ្ឋាន ។
- វិញ្ញាបនបត្របន្តដំណើរការទឹកកកនៅមន្ទីរចំនួន ០២ មូលដ្ឋាន ។
- វិញ្ញាបនបត្របន្តដំណើរការកាត់ដេរនៅមន្ទីរចំនួន ០១ មូលដ្ឋាន ។

- សុំវិញ្ញាបនបត្រដំណើរការបន្តសិប្បកម្មទឹកសណ្តែកនៅមន្ទីរចំនួន ០១ មូលដ្ឋាន ។
- វិញ្ញាបនបត្របន្តដំណើរការទឹកត្រីនៅមន្ទីរចំនួន ០១ មូលដ្ឋាន ។
- សុំវិញ្ញាបនបត្រដំណើរការ សិប្បកម្មស្មោរអំបិលអ៊ីយ៉ូដនៅមន្ទីរចំនួន ០១ មូលដ្ឋាន ។
- សុំវិញ្ញាបនបត្រដំណើរការបន្តម៉ាស៊ីនកិនស្រូវនៅមន្ទីរចំនួន ០១ មូលដ្ឋាន ។
- សុំវិញ្ញាបនបត្រដំណើរការបន្តសិប្បកម្មក្រឡឹង និង ផ្សារដែក នៅមន្ទីរចំនួន ១១ មូលដ្ឋាន ។
- សុំចុះបញ្ជី និង វិញ្ញាបនបត្រដំណើរការសិប្បកម្មកាត់ដេរនៅមន្ទីរចំនួន ០២ មូលដ្ឋាន ។
- សុំចុះបញ្ជី និង វិញ្ញាបនបត្រដំណើរការសិប្បកម្មផលិតទឹកពិសាដបនៅមន្ទីរចំនួន ១២ មូលដ្ឋាន ។
- សុំចុះបញ្ជី និងវិញ្ញាបនបត្រដំណើរការសិប្បកម្ម ទឹកកកដើមនៅមន្ទីរចំនួន ០១ មូលដ្ឋាន ។
- សុំចុះបញ្ជី និង វិញ្ញាបនបត្រដំណើរការសិប្បកម្មនំប៉័ងនៅមន្ទីរចំនួន ០៣ មូលដ្ឋាន និងសុំវិញ្ញាបនបត្រដំណើរការបន្តចំនួន ០១ មូលដ្ឋាន។
- សុំចុះបញ្ជី និង វិញ្ញាបនបត្រដំណើរការសិប្បកម្មក្រឡឹង និង ផ្សាដែកនៅមន្ទីរចំនួន ០៣ មូលដ្ឋាន ។
- រៀបចំសំណុំបែបបទចុះបញ្ជី និងវិញ្ញាបនបត្រផលិតសំបកដបនៅមន្ទីរ ០១ មូលដ្ឋាន ។
- ចុះបញ្ជីនិងវិញ្ញាបនបត្រដំណើរការសិប្បកម្មអ៊ុតខ្លីស័ង្កសីចំនួន ០១ មូលដ្ឋាន ។

* ការងារពិនិត្យគុណភាពផលិតផល

- បានយកផលិតផលទឹកពិសាដបទៅពិនិត្យគុណភាពនៅមជ្ឈមណ្ឌលមន្ទីរពិសោធន៍ជាតិ ផ្នែកមីក្រូជីវសាស្រ្តចំនួន ០៨ មូលដ្ឋាន និង ផ្នែកគីមីសាស្រ្ត ១០ មូលដ្ឋាន ។

- ចុះធ្វើអធិការកិច្ចសិប្បកម្មផលិតទឹកពិសារដបកែលម្អខ្សែសង្វាក់ផលិតកម្ម និង អនាម័យបានចំនួន ១៣ មូលដ្ឋាន ។
- បានយកផលិតផលទឹកកកទៅពិនិត្យគុណភាពនៅមជ្ឈមណ្ឌលមន្ទីរពិសោធន៍ជាតិ ផ្នែកមីក្រូជីវសាស្រ្ត ០២ មូលដ្ឋាន និង ផ្នែកគីមីសាស្រ្ត ០២ មូលដ្ឋាន ។
- បានយកផលិតផលទឹកត្រីទៅពិនិត្យគុណភាពនៅមជ្ឈមណ្ឌលមន្ទីរពិសោធន៍ជាតិផ្នែកគីមីសាស្រ្តចំនួន ០១ មូលដ្ឋាន ។
- មន្ទីរ និង ការិយាល័យបានចូលរួមជាមួយគណៈកម្មការជាតិចុះ ត្រួតពិនិត្យម៉ាស៊ីនបញ្ចូលជាតិអ៊ីយ៉ូដក្នុងអំបិល សិប្បកម្មស្មោអំបិល របស់លោក អ៊ឹង តិចហោ ស្ថិតនៅ ភូមិជ័យឧត្តមបឹងខ្នុម ឃុំព្រែកខ្សាយ (ក) ស្រុកពាមរក៍ ។

* ការងារអធិការកិច្ចៈ

- បានចុះអធិការកិច្ចសិប្បកម្ម ផលិតទឹកក្រូចបានយកវត្ថុធាតុដើមមកត្រួតពិនិត្យ និងធ្វើកិច្ចសន្យាអោយកែលម្អរៀបចំបន្ទប់ធ្វើពីដាន ធ្វើអនាម័យ ដាក់តាំងផ្លាកយីហោ ០១ មូលដ្ឋាន ។
- បានចុះអធិការកិច្ចសិប្បកម្មផលិតទឹកពិសាដប បានធ្វើកិច្ចសន្យាអោយម្ចាស់សិប្បកម្មរៀបចំបន្ទប់ខណ្ឌដាច់ដោយឡែកពីគ្នារវាងផ្នែកម៉ាស៊ីន និងផ្នែកផលិតកម្ម ដាក់តាំងផ្លាកយីហោ និងធ្វើអនាម័យចំនួន ១០ មូលដ្ឋាន ។

* ការងារបណ្តុះបណ្តាលៈ

- មន្ទីរ ការិយាល័យ និងក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានរៀបចំសិក្ខាសាលាស្តីពីសិទ្ធិជនពិការដែលមានការចូលរួមពីម្ចាស់រោងចក្រ និងសិប្បកម្ម ។
- មន្ទីរ ការិយាល័យ និងក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានរៀបចំបណ្តុះបណ្តាលវិធីសាស្រ្តវាយតម្លៃផលប៉ះពាល់លិខិតបទដ្ឋានគតិយុត្តដល់មន្ត្រីរាជការ ពាណិជ្ជករ ឧស្សាហករ សិប្បករនិងធុរជននៅថ្នាក់ក្រោមជាតិ។
- មន្ទីរ និងការិយាល័យបានទៅចូលរួមសិក្ខាសាលា ស្តីពីសិទ្ធិជនពិការ នៅខេត្តរតនៈគិរី ។

## ២-ការងារស្តង់ដារនិងមាត្រាសាស្ត្រ

ក- ការងារស្តង់ដារ

- បានចុះផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធការងារស្តង់ដារដល់រោងចក្រ សិប្បកម្ម បានចំនួន ៣០ មូលដ្ឋាន ។
- បានចុះធ្វើអធិការកិច្ចសិប្បកម្មផលិតទឹកពិសាដបចំនួន ១០ មូលដ្ឋាន ។
- បានចូលរួមវគ្គបណ្តុះបណ្តាលឡជីវឧស្ម័នដុតអង្កាមនៅវិទ្យាស្ថានស្តង់ដារកម្ពុជា ។
- បានចូលរួមវគ្គសិក្ខាសាលាស្តីពីការផ្តល់ព័ត៌មាន និងប្រមូលទិន្នន័យសំរាប់រៀបចំសេចក្តីព្រាងស្តង់ដារ ផ្ការំដួល និងផ្កាច័ន្ទសែនស ថ្ងៃទី១៨ ខែ ឧសភា ឆ្នាំ ២០១៦ នៅសណ្ឋាគារសាន់វេភ្នំពេញ ។
- បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការត្រួតពិនិត្យលើប្រព័ន្ធផលិតកម្មម្ហូបអាហារ ថ្ងៃទី ២១- ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៦ នៅវិទ្យាស្ថានស្តង់ដារកម្ពុជា ។

ខ- ការងារមាត្រាសាស្ត្រ

- ការងារចុះបញ្ជីមាត្រាសាស្ត្រ(ស្ថានីយ៍ ឬ ដេប៉ូប្រេងឥន្ធនៈ) បានចំនួន ១១មូលដ្ឋានក្នុងនោះសុំបន្ត ៩ មូលដ្ឋាន ចុះបញ្ជីថ្មី ២ មូលដ្ឋាន ។
- ទិន្នន័យស្ថិតិស្ថានីយ៍ ឬដេប៉ូប្រេងឥន្ធនៈមានចំនួន ១១៨ មូលដ្ឋាន ចំនួនទូរម៉ាស៊ីនមាន ១៨២ ទូរ ចំនួនដៃបាញ់ប្រេង ៤៧៦ ដៃ ។
- ការងារត្រួតពិនិត្យផ្ទៀងផ្ទាត់ឧបករណ៍មាត្រាសាស្ត្រ ក្នុងនោះត្រួតពិនិត្យដៃបាញ់ប្រេងតាមស្ថានីយ៍ ឬ ដេប៉ូប្រេងឥន្ធនៈ មានចំនួន ១៥៨ មូលដ្ឋាន ។
- សរុបដៃបាញ់ប្រេងមានចំនួន ៦៧១ ដៃ ក្នុងនោះពិនិត្យលើកដំបូងបាន ០៩ មូលដ្ឋាន មាន ៣៨ដៃ ពិនិត្យកំពុងប្រើប្រាស់បាន ១៤៩ មូលដ្ឋាន មានចំនួន ៦៣៣ ដៃ ។
- ទិន្នន័យស្ថិតិ ជញ្ជីងស្ពាន ឬ ជញ្ជីងគោន មានចំនួន ១១ មូលដ្ឋាន ។
- ឧបករណ៍ស្តង់ដារប្រតិបត្តមានចំនួន ០៦មុខ ។

## ៣-ការងារទឹកស្អាត

- ស្ថានភាពនិងស្ថិតិអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត

ទូទាំងខេត្តមានក្រុមហ៊ុនធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតមានប្រកាសអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្មចំនួន ០៨ ក្រុមហ៊ុនកំពុងផលិតនិងបានធ្វើការចែកចាយជូនប្រជាពលរដ្ឋប្រើប្រាស់នៅតាម តំបន់សេវាកម្ម រៀងៗខ្លួន ។ មានក្រុមហ៊ុនមួយចំនួនធំមិនទាន់ពង្រីកបណ្តាញទុយោទឹកទៅតាមតំបន់សេវាកម្មដែល ក្រសួងបានអនុញ្ញាត ។

- មានក្រុមហ៊ុនចំនួន ០២ កំពុងផលិត និងចែកចាយប៉ុន្តែពុំទាន់មានច្បាប់អនុញ្ញាតមានទីតាំងនៅ ឃុំក្រពៅ ស្រុកកំចាយមារ និង ឃុំជើងភ្នំ ស្រុកបាភ្នំ ។

- មានក្រុមហ៊ុន ០១ កំពុងសាងសង់រោងចក្រ និងមានប្រកាសអនុញ្ញាតពីក្រសួង សំណង់សំរេចបាន ៩០% មានទីតាំងនៅ ភូមិព្រៃកឈ្មោះ ឃុំព្រៃកតាសរ ស្រុកពោធិ៍រៀង ។

- មានក្រុមហ៊ុន ០៧ កំពុងសិក្សាសម្ថិទ្ធិលទ្ធភាព ។

- មានក្រុមហ៊ុន ០២ ក្រសួងបានវាយតម្លៃរួចមិនទាន់ចេញប្រកាស ។

- ណែនាំអោយអាជីវករផ្គត់ផ្គង់ទឹកស្អាតពង្រីកបណ្តាញទៅតាមផែនការដែលក្រសួងបានកំណត់ និងធ្វើការលាងសំអាតអាងទឹកជាប្រចាំ ដើម្បីជៀសវាងនូវភាពល្អក់កករ ។

- ស្វែងយល់នូវការផ្គត់ផ្គង់ទឹកស្អាតដល់ទីប្រជុំជនបន្ថែមទៀត ។

- ដាស់តឿនអាជីវករអោយផ្តល់របាយការណ៍ទៀងទាត់ជូនមកមន្ទីរនិងបញ្ចូលទិន្នន័យតាមប្រព័ន្ធ WSMS មានរបាយការណ៍ប្រចាំត្រីមាស ឆ្នាំ និងលទ្ធផលវិភាគទឹក ។

- អោយបញ្ចុះតំលៃទឹកទៅតាមពេលវេលាដែលអាចធ្វើបាន ។

- បានចុះត្រួតពិនិត្យមូលដ្ឋានទឹកស្អាត ។

- លោកប្រធានមន្ទីរបានចូលរួមសិក្ខាសាលាជាច្រើនលើកនៅភ្នំពេញ សិក្ខាសាលាខ្លះមានកិច្ចសហការពីកូរ៉េ និងជប៉ុន ។

- បានអញ្ជើញអាជីវករធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតទូទាំងខេត្តចូលរួមប្រជុំនៅមន្ទីរជារៀងរាល់ខែ ។

- បានយកទឹកទៅពិនិត្យនៅមជ្ឈមណ្ឌលមន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជា ។

- បានអញ្ជើញអាជីវករមករៀនបញ្ចូលប្រព័ន្ធ WSMS ពីនាយកដ្ឋានទឹកស្អាត ។

- បានយកទឹកទៅពិនិត្យគ្រប់ក្រុមហ៊ុន រយៈពេល០៣ខែម្តង ។

- បានចូលរួមកិច្ចប្រជុំ និង ផ្តល់យោបល់លើការវាយតម្លៃសំណើសុំប្រកាសអនុញ្ញាតផ្ទាល់ ជាមួយលោកប្រធានមន្ទីរនៅភ្នំពេញ ចំនួនពីរលើក ។

- បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើ សេចក្តីណែនាំបច្ចេកទេសសម្រាប់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតខ្នាតតូច ។

- បានអញ្ជើញអាជីវករធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតទូទាំងខេត្តមកប្រជុំធ្វើផែនការ ០៣ ឆ្នាំ និង ០៥ ឆ្នាំ និង២០ឆ្នាំ ។

**៤-ការងាររដ្ឋបាល**

*ស្ថានភាពគ្រប់គ្រងមន្ត្រីរាជការ:

- មន្ត្រីក្របខ័ណ្ឌសរុបចំនួន:១៥នាក់,ក្នុងនេះស្រី២នាក់
- មន្ត្រីជាប់កិច្ចសន្យាចំនួន ០៣ នាក់ ក្នុងនេះស្រីមានចំនួន ០២នាក់
- ការគ្រប់គ្រងមន្ត្រីរាជការគឺអនុវត្តការចុះបញ្ជីវត្តមានជាប្រចាំថ្ងៃតាមការិយាល័យ ។
- អនុវត្តការប្រជុំមន្ត្រីរាជការរបស់មន្ទីរ ជារៀងរាល់ ១ ខែម្តង ។

* ការងារបៀវត្ស:

- បានបំពេញសំណុំបែបបទសំរាប់ការបើកប្រាក់បៀវត្សតាមប្រព័ន្ធធនាគារជូនមន្ត្រីបានទាន់ពេលវេលា ។

- បានរៀបចំសំណុំបែបបទតម្លើងប្រាក់បៀវត្សប្រចាំឆ្នាំ ២០១៦ ជូនមន្ត្រីរាជការចំនួន ១១ នាក់ តែមិនទាន់ទទួលបានលទ្ធផលឆ្លើយតបនៅឡើយ ។

- បានរៀបចំសំណុំបែបបទតម្លើងថ្នាក់បៀវត្សប្រចាំឆ្នាំ ២០១៧ ចំនួន ៨ នាក់ ។

* កាងារបណ្តុះបណ្តាល:

- មន្ទីរបានរៀបចំកម្មវិធីនិងធ្វើការបណ្តុះបណ្តាលវិធីសាស្ត្រវាយតម្លៃផលប៉ះពាល់លិខិតបទដ្ឋានគតិយុត្តដល់មន្ត្រីរាជការ ពាណិជ្ជករ ឧស្សាហករ សិប្បករ និងធុរជនដែលមានការពាក់ព័ន្ធនៅមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តព្រៃវែង ។

- មន្ទីរបានបើកកិច្ចប្រជុំផ្សព្វផ្សាយស្តីពីការប្រយុទ្ធនិងជំងឺអេដស៍នៅសាលប្រជុំមន្ទីរឧស្សាហកម្ម - និងសិប្បកម្មខេត្ត ។

- មន្ទីរបានប្រារព្ធពិធីប្រគល់ទឹកបរិសុទ្ធអង្គរព្យ៍ចំនួន ៥.០០០ កេសដល់រដ្ឋបាលខេត្តព្រៃវែងក្រោមអធិបតីភាពឯកឧត្តម សយ ភីរម្យ អនុរដ្ឋលេខាធិការតំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តម បណ្ឌិត ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ។

- មន្ទីរបានទទួលមន្ត្រីមុខងារសាធារណៈចុះត្រួតពិនិត្យបុគ្គលិកកិច្ចសន្យានៅមន្ទីរឧស្សាហកម្មនិងសិប្បកម្ម
- មន្ទីរបានបើកកិច្ចប្រជុំផ្សព្វផ្សាយច្បាប់ស្តីពី កិច្ចការពារ និង ការលើកកម្ពស់សិទ្ធិជនពិការ និង ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០១៤-២០១៨ ដល់មន្ត្រីរាជការ និង មន្ត្រីកិច្ចសន្យា នៅមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តព្រៃវែង ។

- មន្ទីរបានបើកកិច្ចប្រជុំប្រចាំខែជាមួយមន្ត្រី ដើម្បីរាយការពីសកម្មភាពផ្សេងៗរបស់មន្ទីរ និងបានផ្សព្វផ្សាយផែនការស្តីពីកិច្ចការការពារចុះឈ្មោះបោះឆ្នោតដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មីឆ្នាំ២០១៦ ការត្រួតពិនិត្យឈ្មោះ និង ចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និង ការបោះឆ្នោតថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ចាប់ពីឆ្នាំ២០១៦ ដល់ ឆ្នាំ ២០១៩ និងផ្សព្វផ្សាយស្តីពីអត្ថប្រយោជន៍ថ្មីពីការប្រើប្រាស់សេវាកម្មប្រាក់បៀវត្សមន្ត្រីរាជការនៅធនាគារកាណាឌីយ៉ា។

- សវនកម្មផ្ទៃក្នុងបានចុះមកធ្វើអធិការកិច្ចនៅមន្ទីរចាប់ពីថ្ងៃទី១២ដល់ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ ២០១៦។

- ក្រសួងបានចុះត្រួតពិនិត្យការងារនៅមន្ទីរដែលមានប្រតិភូក្រសួងដឹកនាំដោយ លោកជំទាវរដ្ឋលេខាធិការ ឡាយ ណាវែន ចំនួន ពីរលើក។

* ការងារលិខិតស្នាម:

- បានទទួលលិខិតចូលចំនួន: ១៨១ ច្បាប់ និងលិខិតចេញមានចំនួន: ៣៣៣ ច្បាប់ ។

**II- ការចូលរួមក្នុងសកម្មភាពផ្សេងៗរបស់ថ្នាក់ដឹកនាំមន្ទីរ:**

- កិច្ចប្រជុំស្តីពីការងារមាត្រាសាស្ត្រ និងបញ្ហាប្រឈម (១៩/០១/១៦) ។

- សិក្ខាសាលាស្តីពី ធុរៈកិច្ចវិស័យទឹកស្អាតកម្ពុជា-ជប៉ុន (២៥-២៦/០១/១៦) ។

- សិក្ខាសាលាស្តីពីការផ្សព្វផ្សាយឯកសារគតិយុត្ត ដល់ប្រតិបត្តិករទឹកស្អាតឯកជន (២៧/០១/១៦) ។

- សន្និបាតបូកសរុបលទ្ធផលការងារក្រសួងឧស្សាហកម្ម និងសិប្បកម្មឆ្នាំ២០១៥ និង ទិសដៅឆ្នាំ ២០១៦ (០១-០៣/០២/១៦) ។

- វគ្គបណ្តុះបណ្តាលស្តីពីការរៀបចំអង្គភាពថវិកា និង ថវិកាកម្មវិធី ដែលរៀបចំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅសណ្ឋាគារ សុខាភ្នំពេញ (១០/០២/១៦) ។

- កិច្ចប្រជុំផ្ទេរភារកិច្ចថ្នាក់អគ្គនាយក នៅរោងចក្រទឹកស្វយ័តក្រុងភ្នំពេញ (០១/០៣/១៦) ។

- កិច្ចប្រជុំស្តីពីការធ្វើផែនការក្របខណ្ឌសម្រាប់ឆ្នាំ២០១៧ (១៨/០៣/១៦) ។

- វគ្គបណ្តុះបណ្តាលស្តីពី(កម្មវិធីផែនការសុវត្ថិភាពទឹក) នៅទីរួមខេត្តកំពង់ចាម (២៨-៣០/០៣/១៦) ។

- កិច្ចប្រជុំស្តីពីការពិភាក្សាពិនិត្យលើផែនការសកម្មភាពបញ្ចូលជាតិអ៊ីយ៉ូដក្នុងអំបិលជាសកលនៅព្រះរាជាណាចក្រកម្ពុជា (១១/០៤/១៦) ។

- ប្រជុំនៅខេត្តមណ្ឌលគិរី (២៥/០៤/១៦) ។

- ប្រជុំអឌ្ឍមាសនៅក្រសួង (២៧/០៤/១៦) ។

- កិច្ចប្រជុំអឌ្ឍមាស និងពិធីប្រកាសតែងតាំងមុខតំណែងឯកឧត្តមអនុរដ្ឋលេខាធិការ និង ឯកឧត្តមទីប្រឹក្សាក្រសួង (០៥/០៥/១៦) ។

- សិក្ខាសាលាស្តីពីវឌ្ឍនភាពវិស័យទឹកស្អាតទីប្រជុំជនទូទាំងប្រទេស (២៦/០៥/១៦) ។

- សិក្ខាសាលាស្តីពីដំណើរការ និងសារៈសំខាន់នៃការដោះស្រាយវិវាទពាណិជ្ជកម្មតាមយន្តការមជ្ឈត្តការ (២៧/០៥/១៦) ។

- កិច្ចប្រជុំអឌ្ឍមាស និងពិធីប្រកាសតែងតាំងមុខតំណែងអគ្គនាយកកិច្ចការទូទៅ (០៥/០៧/១៦) ។

- ពិធីសម្ពោធដាក់ឱ្យដំណើការ ជាផ្លូវការប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតនៅទីរួមខេត្តបាត់ដំបង (២១/០៧/១៦) ។

- កិច្ចប្រជុំ និងផ្តល់យោបល់ លើការវាយតម្លៃសំណើសុំប្រកាសអនុញ្ញាតផ្ទាល់ ចំនួន ០៦ ទីតាំង (០៨/០៨/១៦) ។

- កិច្ចប្រជុំ និងផ្តល់យោបល់ លើការវាយតម្លៃសំណើសុំប្រកាសអនុញ្ញាតផ្ទាល់ (១៥/០៨/១៦) ។

- សិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីណែនាំបច្ចេកទេសសម្រាប់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតខ្នាតតូច (២៥/០៨/១៦) ។

- ពិធីបើកសម្ពោធជាផ្លូវការ និង ទស្សនាស្វែងយល់ពិព័រណ៍ឧស្សាហកម្មយានយន្តកម្ពុជា-អន្តរជាតិ និងពិព័រណ៍ឧស្សាហកម្មវាយនភ័ណ្ឌ និងឧស្សាហកម្មកាត់ដេរ កម្ពុជា-អន្តរជាតិ ឆ្នាំ២០១៦ ។

- ប្រជុំផ្សព្វផ្សាយ ច្បាប់ស្តីពីកិច្ចការពារ និង ការលើកកម្ពស់សិទ្ធិជនពិការ និង ផែនការយុទ្ធសាស្ត្រស្តីពីពិការភាព ២០១៤- ២០១៨ នៅទីរួមខេត្តរតនគិរី (០៦/០៩/២០១៦)។

- សិក្ខាសាលាស្តីពី "ការពង្រឹងការអនុវត្តបទប្បញ្ញត្តិក្នុងការផលិត និងការចរាចរអំបិលអ៊ីយ៉ូដនៅកម្ពុជា" (១៣/១០/១៦) ។

- សិក្ខាសាលាពិគ្រោះយោបល់ស្តីពី ការផ្ទេរមុខងារ និងធនធានឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ (២០/១០/១៦) ។

- សិក្ខាសាលាស្តីពី ការវាយតម្លៃផលប៉ះពាល់លិខិតបទដ្ឋានគតិយុត្ត (២៥/១០/១៦) ។

- សិក្ខាសាលាផ្សព្វផ្សាយស្តីពី " Trade SWAP EIF- Tier 2 CEDEP II ត្រួតពិនិត្យ និង វាយតម្លៃលទ្ធផលសម្រេចបាន និងផលប៉ះពាល់ក្រោមកម្មវិធីពង្រឹងសមាហរណកម្ម " (០១/១១/១៦) ។

- កិច្ចប្រជុំស្តីពីការត្រួតពិនិត្យ ការអនុវត្តផែនការលទ្ធកម្ម ឆ្នាំ ២០១៦ (០៨/១១/១៦) ។

- ពិធីប្រកាសតែងតាំងមុខដំណែងមន្ត្រីជាន់ខ្ពស់ក្រសួងឧស្សាហកម្ម និង សិប្បកម្ម (០៨/១១/១៦) ។

ឆ្លងតាមរយៈការអញ្ជើញពីគណៈអភិបាលខេត្ត មន្ទីរបានចូលរួមពិធីនិងសកម្មភាពរបស់ថ្នាក់ដឹកនាំដូចជា៖

- ពិធីប្រកាសចូលកាន់មុខតំណែងអនុប្រធានទទួលបន្ទុកការងាររួមនៃមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្តព្រៃវែង (០៤/០១/១៦) ។

- ពិធីប្រកាស ចូលកាន់មុខតំណែង អភិបាល នៃគណៈអភិបាលខេត្តព្រៃវែង (០៥/០១/១៦) ។

- ពិធីមិទ្ទិញអបអរសាទរខួបអនុស្សាវរីយ៍ លើកទី ៣៧ ទិវាជ័យជំនះ ៧ មករា (០៦/០១/១៦) ។

- កិច្ចប្រជុំស្តីពីការត្រួតពិនិត្យ វាយតម្លៃលទ្ធផលការងារ បញ្ហាប្រឈមនានា និងដាក់ចេញទិសដៅអនុវត្តការងារបន្ត (១៩/០១/១៦) ។

- កម្មវិធីសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ ២០១៥ និងទិសដៅការងារឆ្នាំ២០១៦ របស់រដ្ឋបាលខេត្តព្រៃវែង (២៦-២៧/០១/១៦) ។

- កិច្ចប្រជុំស្តីពីការត្រួតពិនិត្យ វាយតម្លៃផ្សារកអណ្តើក (០២/០២/១៦) ។

- ពិធីផ្សព្វផ្សាយខ្លឹមសារ សង្ឃប្រកាស អនុសំវច្ឆរៈ មហាសន្និបាតមន្ត្រីសង្ឃលើកទី ២៤ (០៣/០២/១៦) ។

- ពិធីប្រកាសចូលកាន់មុខតំណែងអភិបាល នៃគណៈអភិបាលក្រុងព្រៃវែង(០៥/០២/១៦) ។

- ពិធីសម្ពោធឆ្លងសមិទ្ធផលនានា ក្នុងវត្តកណ្តាច់ ឃុំចុងអំពិល ស្រុកកញ្ជ្រៀច (១១/០២/១៦) ។

- ប្រជុំស្តីពីការបញ្ចប់កិច្ចសន្យាសាងសង់ដំបូល និងចាក់សាបផ្សារកអណ្តើក (១២/០២/១៦) ។

- ពិធីប្រកាសចូលកាន់មុខដំណែងអភិបាល នៃគណៈអភិបាលស្រុកពោធិ៍រៀង (១៥/០២/១៦) ។

- កិច្ចប្រជុំការងារពាក់ព័ន្ធកិច្ចការគ្រប់គ្រង និងប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យា (១៧/០២/១៦) ។

- ពិធីបុណ្យបញ្ចុះខ័ណ្ឌសីមា ពុទ្ធាភិសេក និង ឆ្លងសាលាបឋមសិក្សា វត្តទួលមានជ័យ ហៅវត្តទួលជ្រៃ ស្រុកស៊ីធរកណ្តាល (២១/០២/១៦) ។

- ពិធីបុណ្យឆ្លងឧបដ្ឋានសាលា និង សមិទ្ធផលនានា ក្នុងវត្តព្រហ្សិត (២២/០២/១៦) ។

- ពិធីប្រារព្ធទិវាទីក្រុងស្អាតលើកទី៤ ឆ្នាំ២០១៦ (១០/០៣/១៦) ។

- ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ អគារប៉ុស្តិ៍រដ្ឋបាល ឃុំរោងដំរី ស្រុកបាភ្នំ (១៧/០៣/១៦) ។

- វគ្គបណ្តុះបណ្តាលស្តីពី ការចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម (១៨/០៣/១៦) ។

- ពិធីសម្ពោធឆ្លងសមិទ្ធផលនានា ក្នុងវត្តពោធិដ្ឋាន ហៅវត្តថ្លារ (១៩/០៣/១៦) ។

- ពិធីបុណ្យបញ្ចុះខណ្ឌសីមា វត្តសិម្ពលី ឃុំស្តៅកោង ស្រុកបាភ្នំ (១៩/០៣/១៦) ។

- កិច្ចប្រជុំស្តីពីការពង្រឹងវិធានការប្រយុទ្ធប្រឆាំងគ្រឿងញៀន និងទិសដៅការងារប្រយុទ្ធប្រឆាំងគ្រឿងញៀនឆ្នាំ២០១៦ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន (២៣/០៣/១៦) ។

- ពិធីបញ្ចុះខ័ណ្ឌសីមា និងសម្ពោធដាក់ឲ្យប្រើប្រាស់សមិទ្ធផលនានា វត្តពោធិ៍សិរីសាគរ (២៦/០៣/១៦) ។

- ពិធីប្រកាសផ្ទេរភារកិច្ច និងតែងតាំង អភិបាល នៃគណៈអភិបាលស្រុកពាមរក៍ (២៩/០៣/១៦) ។

- កិច្ចប្រជុំស្តីពី ការបង្ហាញលទ្ធផលប្លង់គោលប្រើប្រាស់ដីធ្លី ក្នុងក្រុងព្រៃវែង និង ទីប្រជុំជនស្រុកស្វាយអន្ទរ (៣១/០៣/១៦) ។

- សន្និបាតបូកសរុបសមិទ្ធិផលសុខាភិបាល ( ០១/០៤/២០១៦ ) ។

- ពិធីបញ្ចុះខណ្ឌសីមាពុទ្ធាភិសេកនិងសម្ពោធឆ្លងសមិទ្ធផលនានាក្នុងវត្តសទ្ធារាម ហៅវត្តគុំនុំ (០២/០៤/១៦)

- កម្មវិធីសង្គ្រានស្រុកខ្មែរដែលរៀបចំដោយសហព័ន្ធយុវជនកម្ពុជាខេត្តព្រៃវែង(០៣/០៤/១៦)

- កិច្ចប្រជុំពិភាក្សា ស្តីពីបញ្ហាគ្រៀម និងបង្កាសង្គ្រោះបញ្ហាខ្វះទឹក (២៧/០៤/១៦) ។

- ពិធីប្រារព្ធខួបអនុស្សាវរីយ៍លើកទី១៣០ទិវាពលកម្មអន្តរជាតិ (០១/០៥/១៦) ។

- ការផ្សព្វផ្សាយសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៦ (០២/០៥/២០១៦ ) ។

- កិច្ចប្រជុំសាមញ្ញលើកទី២៨អាណត្តិទី២របស់ក្រុមប្រឹក្សាខេត្តព្រៃវែង (០៥/០៥/១៦) ។

- ត្រួតពិនិត្យលទ្ធផលការអនុវត្តន៍ការងារ និង បញ្ហាប្រឈមនានារបស់ក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ក្រុង ស្រុក ត្រីមាសទី០១ ឆ្នាំ ២០១៦ (០៥/០៥/១៦) ។

- ពិធីប្រារព្ធទិវាអន្តរជាតិស្តីពីគ្រួសារ ១៥ ឧសភា ឆ្នាំ ២០១៦ (១២/០៥/១៦) ។

- ពិធីប្រកាសចូលកាន់តំណែងអភិបាលរងនៃគណៈអភិបាលខេត្ត និង នាយករដ្ឋបាលសាលាខេត្ត ( ០៣/០៦/១៦) ។

- ពិធីប្រគល់ទឹកសុទ្ធរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ( ០៣/០៦/១៦) ។

- ពិធីដាំកូនឈើក្នុងពិធីប្រារព្ធធ្វើទិវា(បរិស្ថានជាតិ និងបរិស្ថានពិភពលោក) (០៥/០៦/១៦) ។

- វគ្គបណ្តុះបណ្តាលប្រមូលទិន្នន័យចងក្រងផលិតផលក្នុងស្រុកសរុប (GDP)និង(CPI) (០៦-១០/០៦/១៦) ។

- ពិធីបុណ្យឆ្លងឧបដ្ឋានសាលា និង សមិទ្ធផលនានាវត្តបទុមរត៍ (ហៅវត្តតាកោ) (០៩/០៦/១៦) ។

- ពិធីចម្រើនព្រះបរិត្តនមស្សសការព្រះរតនត្រ័យថ្វាយព្រះរាជកុសលក្នុងព្រះរាជពិធីចម្រើនព្រះជន្ម ថ្វាយសម្តេច ព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ព្រះប្រធានកិត្តិយសកាកបាទក្រហមកម្ពុជា ( ១៨/០៦/១៦)។

- កិច្ចប្រជុំអាណត្តិប្រចាំខែ មិថុនា (២០/០៦/១៦) ។

- ទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ២៦ មិថុនា (០៥/០៧/១៦) ។

- ពិធីអបអរសាទរបុណ្យរុក្ខទិវា ០៩ កក្កដា (០៧/០៧/២០១៦ ) ។

-វគ្គបណ្តុះបណ្តាលស្តីពី“ការពង្រឹងសមត្ថភាពក្នុងការដោះស្រាយវិវាទការងារ ការទប់ស្កាត់ និងដោះស្រាយបញ្ហាកូដកម្ម បាតុកម្ម” (១២/០៧/១៦) ។

- ពិធីប្រគេនទៀនព្រះវស្សា (១៨/០៧/១៦) ។

- សិក្ខាសាលាថ្នាក់ខេត្ត ស្តីពីដំណើរការរៀបចំផែនការត្រៀមបម្រុង ឆ្លើយតបគ្រោះអាសន្ន ដោយរួមបញ្ចូលការគ្រប់គ្រងហានិភ័យការប្រែប្រួលអាកាសធាតុ (១៩/០៧/១៦) ។

- ស្វែងយល់ “ផលប៉ះពាល់ក្នុងការអនុវត្តន៍ច្បាប់ លិខិតបទដ្ឋានគតិយុត្តិនានារបស់រាជរដ្ឋាភិបាល និងកិច្ចការពាក់ព័ន្ធសមត្ថកិច្ចទទួលខុសត្រូវរបស់គណកម្មការ” (២០/០៧/១៦) ។

- ពិធីផ្សព្វផ្សាយឯកសារបំរើការងារបោះឆ្នោត និងក្រុមការងារចលនាតាមមជ្ឈដ្ឋាននានា (២២/០៧/១៦) ។

- សិក្ខាសាលាស្តីពី ការអនុវត្តន៍ការងាររៀបចំប្លង់គោលប្រើប្រាស់ដីទីប្រជុំជន ស្វាយអន្ទរ និង ក្រុងព្រៃវែង (២២/០៧/១៦) ។

- ពិធីប្រគល់ ទទួលត្រាផ្លូវការ របស់លេខាធិការដ្ឋានរដ្ឋបាល សាលាដំបូងខេត្តព្រៃវែង (២៥/០៧/១៦) ។

- ប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆមាសទី១ ឆ្នាំ ២០១៦ និងលើកទិសដៅអនុវត្តបន្ត (២៦/០៧/១៦) ។

- ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំចំនួន ០៧ ក្នុងស្រុកកញ្ជ្រៀច និងស្រុកស្វាយអន្ទរ

(២៧/០៧/២០១៦ ) ។

- វគ្គបណ្តុះបណ្តាល ស្តីពី "ការពង្រឹងសមត្ថភាពការអនុវត្តលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល " (២៨/០៧/១៦) ។

- ពិធីជួបសំណេះសំណាល និងពិភាក្សាការងារ គណៈកម្មការទី ៩ នៃរដ្ឋសភា ជាមួយអាជ្ញាធរខេត្ត និងមន្ទីរជំនាញនានា (០៣/០៨/១៦) ។

- កិច្ចប្រជុំសាមញ្ញលើកទី ២៧ អាណត្តិទី២ របស់ក្រុមប្រឹក្សាខេត្តព្រៃវែង (០៤/០៨/១៦) ។

- ពិធីប្រគល់ ទទួលគ្រាផ្លូវការ របស់លេខាធិការដ្ឋានរដ្ឋបាល សាលាដំបូងខេត្តព្រៃវែង (០៤/០៨/១៦) ។

- កិច្ចប្រជុំស្តីពី ផែនការសកម្មភាពការងាររបស់រដ្ឋបាលខេត្ត (០៥/០៨/១៦) ។

- ពិធីបិទការប្រកួតកីឡាមហាជនដណ្តើមពានរង្វាន់សម្តេចក្រឡាហោម ស ខេង ឆ្នាំ២០១៦(០៧/០៨/១៦)។

- ពិធីសម្ពោធស្ពានកំពង់ខ្សាច់ និងបញ្ចុះបឋមសិលាសាងសង់អគារវិទ្យាល័យ ហ៊ុន សែន ពោធិ៍រៀង (០៨/០៨/១៦) ។

- ពិធីបញ្ចុះបឋមសិលាសាងសង់សាលាបឋមសិក្សាពោធិ៍ព្រឹក្សា ឃុំព្រាល និងសាលាអនុវិទ្យាល័យ ត្នោត ឃុំត្នោត ស្រុកកញ្ច្រៀច (០៩/០៨/១៦) ។

- ប្រជុំការបូកសរុបលទ្ធផលការងារ ភូមិ ១ ផលិតផល ១ ។

- កិច្ចប្រជុំណែនាំដើម្បីកំណត់ និងរៀបចំសំណើគម្រោងវិនិយោគ (ជំហានទី១) (១៥/១៨/១៦) ។

- ពិធីផ្សព្វផ្សាយច្បាប់ ស្តីពីការហាមឃាត់អាវុធគីមី អាវុធនុយក្លេអ៊ែរ អាវុធជីវសាស្ត្រ និង អាវុធវិទ្យុសកម្ម (១៧/០៨/១៦) ។

- ពិធីបុណ្យឆ្លងឧបដ្ឋានសាលាវត្តមេសាង (២០/០៨/១៦) ។

- បដិសណ្ឋារកិច្ច សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ (២៤/០៨/១៦) ។

- សិក្ខាសាលាស្តីពីការពិនិត្យកែសម្រួលសេចក្តីព្រាងសៀវភៅផែនការត្រៀមឆ្លើយតបគ្រោះអាសន្នសម្រាប់ឆ្នាំ ២០១៦ ( ២៥/០៨/១៦ ) ។

- កិច្ចប្រជុំផ្សព្វផ្សាយច្បាប់ ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ និងការងារឆមាសទី១ ឆ្នាំ ២០១៦ , កម្មវិធីប្រគល់-ទទួលនូវសម្ភារៈ កុំព្យូទ័រ ម៉ាស៊ីនព្រីន និង បំពាក់បន្ទះពន្លឺព្រះអាទិត្យ ដល់ខេត្តចំនួន ៦ ក្នុងគម្រោង ADB (២៩/០៨/១៦) ។

- ប្រជុំគណៈបញ្ជាការឯកភាពខេត្ត (៣១/០៨/១៦) ។

- កិច្ចប្រជុំសាមញ្ញលើកទី២៨ អាណត្តិទី២ របស់ក្រុមប្រឹក្សាខេត្ត (០៥/០៩/១៦) ។

- ប្រជុំគណៈបញ្ជាការឯកភាពរដ្ឋបាលខេត្ត ( ០៦/០៩/១៦ ) ។

- មិទ្ទិញអបអរសាទរទិវាអក្ខរកម្មជាតិ អន្តរជាតិ ៨ កញ្ញា ឆ្នាំ ២០១៦ ( ០៦/០៩/១៦) ។

- ប្រជុំស្តីពី ការតាមដាន និងផ្ទៀងផ្ទាត់ទិន្នន័យស្ថិតិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសម្រាប់ឆមាសទី១ ឆ្នាំ ២០១៦ (០៦/០៩/១៦) ។

- កិច្ចប្រជុំពិនិត្យពង្រាងស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច តាមមន្ទីរជំនាញសម្រាប់បញ្ចូលក្នុង ឯកសារកម្មវិធីវិនិយោគខេត្តបីឆ្នាំរំកិល (២១/០៩/១៦) ។

- កិច្ចប្រជុំជាមួយក្រុមការងារភូមិភាគទី១ ដែលទទួលខុសត្រូវការត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និង យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការពិភាក្សា និងវាយតម្លៃអំពីចំណុចខ្លាំង ចំណុចខ្សោយ និងអនុសាសន៍ក្នុងការចាត់តាំងអនុវត្ត ដើម្បីពង្រឹងរចនាសម្ព័ន្ធ និងការស្វែងរកដំណោះស្រាយ (២៦/០៩/១៦) ។

- កិច្ចប្រជុំសាមញ្ញលើកទី២៩ អាណត្តិទី២ របស់ក្រុមប្រឹក្សាខេត្ត (០៤/១០/១៦) ។

- ពិធីប្រកាសចូលកាន់មុខដំណែងអភិបាល និង អភិបាលរងស្រុក មេសាង (១៣/១០/១៦) ។

- ពិធីបើក វគ្គបណ្តុះបណ្តាល បដិសណ្ឋារកិច្ច សេវាកម្មទេសចរណ៍ (១៨-២០/១០/១៦) ។

- កិច្ចប្រជុំស្តីពីការរៀបចំផែនការសកម្មភាពចាំបាច់មួយចំនួនមុនដំណើរការសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ក្រុងស្រុក (២៥/១០/១៦) ។

- សិក្ខាសាលាសមាហរណកម្មនៃកម្មវិធីវិនិយោគខេត្ត (២៧/១០/១៦) ។

- ពិធីប្រកាសផ្ទេរភារកិច្ច ប្រធាន គណៈកម្មាធិការសហភាពសហព័ន្ធយុវជនកម្ពុជាខេត្ត (៣០/១០/១៦) ។

- ពិធីបើកបវេសនកាលឆ្នាំសិក្សា ២០១៦- ២០១៧ វិទ្យាល័យ ហ៊ុន សែន កំពង់លាវ (០១/១១/១៦) ។

- សិក្ខាសាលាផ្សព្វផ្សាយព្រះរាជក្រឹត្យ ស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ (០៣/១១/១៦) ។

- កិច្ចប្រជុំសាមញ្ញលើកទី ៣០ អាណត្តិទី២ របស់ក្រុមប្រឹក្សាខេត្ត (០៣/១១/១៦) ។

- កិច្ចប្រជុំស្តីពីការត្រួតពិនិត្យការអនុវត្តផែនការលទ្ធកម្ម ឆ្នាំ ២០១៦ (០៤/១១/១៦) ។

- កិច្ចប្រជុំផ្សព្វផ្សាយសារាចរណែនាំ ស្តីពីការបិទបញ្ជីចំណូល-ចំណាយថវិកា និងការធ្វើរបាយការណ៍បូកសរុបការអនុវត្តចំណូល-ចំណាយថវិកាថ្នាក់ជាតិ ឆ្នាំ ២០១៦ (០៤/១១/១៦) ។

- ពិធីបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា (០៩/១១/១៦) ។

- ពិធីសម្ពោធដាក់ឲ្យដំណើរការជាផ្លូវការនូវ មជ្ឈមណ្ឌលការងារ ខេត្តព្រៃវែង (១០/១១/១៦) ។

- កិច្ចប្រជុំរៀបចំបដិសណ្ឋារកិច្ច សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា (១៧/១១/១៦) ។

- កិច្ចប្រជុំរៀបចំផែនការសកម្មភាព របស់ គណៈកម្មការខេត្ត ជំរុញចលនាភូមិ ១ ផលិតផល ១ ខេត្ត (២២/១១/១៦) ។

- វគ្គបណ្តុះបណ្តាលស្តីពីការត្រួតពិនិត្យ លើប្រព័ន្ធផលិតកម្មម្ហូបអាហារ ( ២១-២៥/១១/១៦) ។

- កិច្ចប្រជុំពិភាក្សា និងវាយតម្លៃអំពីចំណុចខ្លាំង ចំណុចខ្សោយ និងការចាត់តាំងអនុវត្តន៍ ដើម្បីពង្រឹងរចនាសម្ព័ន្ធ និងការស្វែងរកដំណោះស្រាយផ្សេងៗ របស់ក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ( ២៣/១១/១៦) ។

- សិក្ខាសាលាសមាហរណកម្ម នៃកម្មវិធីវិនិយោគសង្កាត់នៅថ្នាក់ក្រុង ឆ្នាំ ២០១៧ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ២០១៧ ២០១៩ ក្រុងព្រៃវែង (២៣/១១/១៦) ។

- កិច្ចប្រជុំពិភាក្សាបញ្ចប់តារាង បញ្ជីទិន្នន័យ សហគ្រាស សហគមន៍ ឬសមាគមផលិត និងទិន្នន័យផលិតផលសក្តានុពលក្នុងខេត្ត ( ២៨/១១/១៦) ។

- ពិធីរំលឹកគុណឧទ្ទិសដល់វិញ្ញាណក្ខន្ធសម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម អតីតប្រធានព្រឹទ្ធសភា និងលោកជំទាវ ញ៉ែម សឿន (០២/១២/១៦) ។

- វគ្គបណ្តុះបណ្តាលមូលដ្ឋានស្តីពី ការត្រួតពិនិត្យទំនិញវេចខ្ចប់ (០៥-០៩/១២/១៦) ។

- កិច្ចប្រជុំសាមញ្ញលើកទី ៣១ អាណត្តិទី២ របស់ក្រុមប្រឹក្សាខេត្ត (០៥/១២/១៦) ។

- ពិធីអបអរទិវាអន្តរជាតិអ្នកស្ម័គ្រចិត្ត ០៥ ធ្នូ ឆ្នាំ ២០១៦ (០៧/១២/១៦) ។

## III- ការវាយតម្លៃ និងសន្និដ្ឋានៈ

- ទន្ទឹមនឹងលទ្ធផលដែលអនុវត្តបានខាងលើ ពិនិត្យជារួមឃើញថាៈ មន្ត្រីមួយចំនួនតូចមានការយល់ដឹងពីជំនាញនៅមានកំរិត និងចំណេះដឹង នៅទាបនៅឡើយ ។ ដូច្នេះ ត្រូវទាមទារការបណ្តុះបណ្តាលបន្ថែមលើផ្នែកជំនាញ ពិសេសផ្នែកកុំព្យូទ័រ។ នៅមានកង្វះខាតមន្ត្រីសំរាប់បំពេញការងារនៅមន្ទីរនិងតាមស្រុកដើម្បីឆ្លើយតបទៅនឹងការងារបច្ចុប្បន្ន ជាការចាំបាច់ ។

- ដោយសារ មានការយកចិត្តទុកដាក់ ណែនាំពីថ្នាក់ដឹកនាំក្រសួង ខេត្ត និងមន្ទីរដល់មន្ត្រីទទួលបន្ទុកជំនាញនិមួយៗព្រមទាំងការខិតខំបំពេញនូវតួនាទីភារកិច្ចរៀងៗខ្លួនទទួលបានលទ្ធផលល្អប្រសើរ។

**IV-ទិសដៅការងារបន្ត:**

- ចុះអធិការកិច្ចតាមឧស្សាហកម្មតូច មធ្យម និងសិប្បកម្ម ។
- ចុះណែនាំអោយម្ចាស់ឧស្សាហកម្មតូច មធ្យម និងសិប្បកម្ម អនុវត្តនូវក្បួនផលិតកម្មល្អ និងអនាម័យល្អ។
- បន្តជំរុញការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ-សិប្បកម្មដល់ម្ចាស់រោងចក្រ សិប្បកម្ម ។
- ជំរុញម្ចាស់រោងចក្រ សិប្បកម្ម អាជីវកម្ម ធ្វើច្បាប់ និងសុំបន្តច្បាប់ដែលអស់សុពលភាព ។
- ជំរុញការយកផលិតផលទៅពិនិត្យគុណភាពឲ្យបានទៀងទាត់តាមការកំណត់ ។
- ជំរុញម្ចាស់ក្រុមហ៊ុនអាជីវកម្មទឹកស្អាត អនុវត្តច្បាប់ឲ្យបានត្រឹមត្រូវ ។
- ស្វែងរកដៃគូរទាំងរដ្ឋ និងឯកជនមកវិនិយោគវិស័យទឹកស្អាតនៅទីប្រជុំជនដែលពុំទាន់មានទឹកស្អាត ។
- តម្រូវឲ្យអាជីវករពង្រីកប្រព័ន្ធបណ្តាញទឹកស្អាតទៅតាមសេចក្តីប្រកាសរបស់ក្រសួងដែលបានកំណត់ ។
- ជំរុញការងារស្តង់ដារចុះផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងការងារស្តង់ដារ ។
- ជំរុញនិងសំរបសំរួលការងារត្រួតពិនិត្យផ្ទៀងផ្ទាត់ឧបករណ៍មាត្រាសាស្ត្រ ។
- ជំរុញចុះធ្វើអធិការកិច្ចតាមរោងចក្រ- សិប្បកម្មពាក់ព័ន្ធនឹងចំណីអាហារ ។
- ជំរុញការងារត្រួតពិនិត្យផលិផលទំនិញវេចខ្ចប់ ។
- ជុំរុញផ្សព្វផ្សាយឲ្យម្ចាស់រោងចក្រ សហគ្រាសធ្វើពាក្យស្នើសុំចុះឈ្មោះក្នុងបញ្ជីមាត្រាសាស្ត្រ ។
- ជុំរុញផ្សព្វផ្សាយឲ្យម្ចាស់រោងចក្រ សហគ្រាសធ្វើពាក្យស្នើសុំត្រួតពិនិត្យឧបករណ៍ ។
- ចុះត្រួតពិនិត្យផ្ទៀងផ្ទាត់ឧបករណ៍ ដែលបានដាក់ពាក្យស្នើសុំត្រួតពិនិត្យ ។
- ជំរុញចុះស្រង់ទិន្នន័យស្ថិតិ ឧបករណ៍មាត្រាសាស្ត្រ ។
- ផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងការងារមាត្រាសាស្ត្រ ។

អាស្រ័យដូចសេចក្តីជំរាបជូនខាងលើ សូមឯកឧត្តមទេសរដ្ឋមន្ត្រី មេត្តាជ្រាបជារបាយការណ៍ ។

សូមឯកឧត្តម មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ ។

ព្រៃវែង, ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១៦

**ប្រធានមន្ទីរ**

គួយ_កុសល

មន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តព្រៃវែង

## តារាងស្ថិតិលំអិតតាមផ្នែក និង អនុផ្នែក ប្រចាំ ឆ្នាំ ២០១៦

| លេខកូដ | ផ្នែក និង អនុផ្នែក | ចំនួន | សហគ្រិន | បរិមាណផលិតផល | | ដើមទុន(ដុល្លាអាមេរិក) | | ពលកម្ម | | ចំនួនមូលដ្ឋានចុះបញ្ជី | | | តម្លៃបរិមាណផលិតផល (លានរៀល) | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | មូលដ្ឋាន | ជាស្ត្រី | ឯកត្តា | ចំនួន | ទុនអចល័ត | ទុនសរុប | ស្រី | សរុប | ក្រសួង | មន្ទីរ | សរុប | លក់ក្នុងស្រុក | នាំចេញ | សរុប |
| 10 | កម្មន្តសាលផលិតផលម្ហូបអាហារ | 29 | 2 | 0 | 14,195 | 2,080,835 | 2,956,344 | 6 | 154 | 28 | 1 | 29 | 10,717 | 0 | 10,717 |
| 1013 | ការកែច្នៃនិងថែរក្សាសាច់និងផលិតផលសាច់សត្វបសុបក្សី | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 10136 | ផលិតកម្មប្រហិត | 0 | 0 | 0 | 0 | 0 | | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 1053 | កម្មន្តសាលការ៉េមនិងការ៉េមប្រអប់ ទឹកកក ការ៉េមដើម និងទឹកកកករសជាតិដទៃទៀត | 15 | 1 | 0 | 8,135 | 763,750 | 1,370,180 | 4 | 71 | 14 | 1 | 15 | 1,627 | 0 | 1,627 |
| 10531 | កម្មន្តសាលការ៉េម | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 10532 | កម្មន្តសាលការ៉េមប្រអប់ ការ៉េមដើម និងទឹកកកករសជាតិដទៃទៀត | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 10533 | កម្មន្តសាលទឹកកក និងទឹកកកអនាម័យ | 15 | 1 | 0 | 8,135 | 763,750 | 1,370,180 | 4 | 71 | 14 | 1 | 15 | 1,627 | 0 | 1,627 |
| 1063 | ការកិនអង្ករ/ពោតនិងកម្មន្តសាលម្សៅពីអង្ករ/ពោត | 14 | 1 | 0 | 6,060 | 1,317,085 | 1,586,164 | 2 | 83 | 14 | 0 | 14 | 9,090 | 0 | 9,090 |
| 10631 | ការកិនស្រូវ | 14 | 1 | 0 | 6,060 | 1,317,085 | 1,586,164 | 2 | 83 | 14 | 0 | 14 | 9,090 | 0 | 9,090 |
| 10632 | ការកិនពោត | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 10633 | កម្មន្តសាលម្សៅពីអង្ករ/ពោត | 0 | 0 | 0 | 0 | 0 | 0 | 0 | | 0 | 0 | 0 | 0 | 0 | 0 |
| 10639 | ការកិនអង្ករ/ពោតនិងកម្មន្តសាលម្សៅពីអង្ករ/ពោតដទៃទៀតដែលពុំបានរាប់បញ្ចូល | 0 | 0 | 0 | 0 | | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 1071 | កម្មន្តសាលនំដុត | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 10711 | កម្មន្តសាលនំប៉័ង | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 1077 | កម្មន្តសាលគ្រឿងទេសដែលបានកែច្នៃ ទឹកជ្រលក់និងគ្រឿងផ្សំផ្សេងៗនិងផលិតផលសម្រាប់ធ្វើម្ហូបដទៃទៀត | 0 | 0 | 0 | | | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 10771 | កម្មន្តសាលគ្រឿងទេសដែលបានកែច្នៃនិងគ្រឿងផ្សំផ្សេងៗ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 10772 | កម្មន្តសាលទឹកជ្រលក់ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 107721 | កម្មន្តសាលទឹកត្រី | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 10779 | កម្មន្តសាលគ្រឿងទេសដែលបានកែច្នៃ ទឹកជ្រលក់និងគ្រឿងផ្សំផ្សេងៗនិងផលិតផលសម្រាប់ធ្វើម្ហូបដទៃទៀតដែលពុំបានរាប់បញ្ចូល | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 107791 | ការកែច្នៃអំបិលទៅជាអំបិលពិសារ ដូចជាអំបិលអ៊ីយ៉ូដ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 11 | កម្មន្តសាលភេសជ្ជៈ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 11050 | កម្មន្តសាលទឹកបរិសុទ្ធ និងទឹករ៉ែ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |

| | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 11090 | កម្មន្តសាលកេសជ្ជៈ ដទៃទៀតដែលពុំបានរាប់បញ្ចូល | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 12 | កម្មន្តសាលផលិតផលថ្នាំជក់ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 12010 | កម្មន្តសាលបារីនិងស៊ីហ្គា | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 12090 | កម្មន្តសាលផលិតផលថ្នាំជក់ដទៃទៀតដែលពុំបានរាប់បញ្ចូល | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 13 | កម្មន្តសាលវាយនភណ្ឌ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 1311 | ការរៀបចំនិងការវែសរសៃអំបោះ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 13111 | ការវៃវាយនភណ្ឌកប្បាស | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 13112 | ការវៃវាយនភណ្ឌសូត្រ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 13119 | ការរៀបចំនិងការវែសរសៃអំបោះដទៃទៀតដែលពុំបានរាប់បញ្ចូល | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 1312 | តម្បាញកំណាត់ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 13121 | តម្បាញកំណាត់កប្បាស | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 13122 | តម្បាញកំណាត់សូត្រ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 13129 | តម្បាញកំណាត់ដទៃទៀតដែលពុំបានរាប់បញ្ចូល | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 13130 | ការធ្វើសម្រេចវាយនភណ្ឌ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 1391 | កម្មន្តសាលផ្ទាំងកំណាត់ដោយម្ជុលច្រើនឬមួយ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 13911 | កម្មន្តសាលកំណាត់ចាក់ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 13919 | កម្មន្តសាលផ្ទាំងកំណាត់ដោយម្ជុលច្រើនឬមួយដែលពុំបានរាប់បញ្ចូល | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 13920 | កម្មន្តសាលរបស់តុបតែងពីវាយនភណ្ឌលើកលែងសម្លៀកបំពាក់ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 1393 | កម្មន្តសាលកម្រាលព្រំ និងព្រំតូចៗ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 13931 | កម្មន្តសាលកម្រាលព្រំ និងកន្ទេល | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 14 | កម្មន្តសាលសម្លៀកបំពាក់ | 2 | 0 | 0 | 6,322,949 | 112,230 | 142,230 | 2,085 | 2,280 | 2 | 0 | 2 | 63,229 | 0 | 63,229 |
| 14110 | កម្មន្តសាលសម្លៀកបំពាក់ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 1412 | ការកាត់ដេរសម្លៀកបំពាក់បុរស និងរ៉ូបស្ត្រីតាមតម្រូវការអតិថិជន | 2 | 0 | 0 | 6,322,949 | 112,230 | 142,230 | 2,085 | 2,280 | 2 | 0 | 2 | 63,229 | 0 | 63,229 |
| 20 | កម្មន្តសាលគីមី និងផលិតផលគីមី | 2 | 0 | 0 | 0 | 104,700 | 104,900 | 0 | 10 | 2 | 0 | 2 | 0 | 0 | 0 |
| 2011 | កម្មន្តសាល គីមីមូលដ្ឋាន | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 20111 | កម្មន្តសាល អុកស៊ីសែន និងអ៊ីដ្រូហ្សែន អាសេទីឡែន | 0 | | 0 | | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 20119 | កម្មន្តសាល គីមីមូលដ្ឋានដែលពុំបានរាប់បញ្ចូល | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |

| | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 20120 | កម្មន្តសាល ជីនិងសមាសធាតុនីត្រូហ្សែន | 2 | 0 | 0 | 0 | 104,700 | 104,900 | 0 | 10 | 2 | 0 | 2 | 0 | 0 | 0 |
| 23 | កម្មន្តសាល ផលិតផលពីរ៉ែអលោហៈដទៃទៀត | 7 | 0 | 0 | 8,800,000 | 545,000 | 620,800 | 63 | 92 | 7 | 0 | 7 | 780 | 0 | 780 |
| 23100 | កម្មន្តសាល កញ្ចក់ និងផលិតផលពីកញ្ចក់ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 23910 | កម្មន្តសាល ផលិតផលធន់កម្តៅ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 2392 | កម្មន្តសាល សម្ភារៈសំណង់ធ្វើពីដីឥដ្ឋ | 7 | 0 | 0 | 8,800,000 | 545,000 | 629,800 | 63 | 92 | 7 | 0 | 7 | 780 | 0 | 780 |
| 23921 | កម្មន្តសាល ក្បឿងប្រក់ដំបូល | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 23922 | កម្មន្តសាល ឥដ្ឋ | 7 | 0 | 0 | 8,800,000 | 545,000 | 629,800 | 63 | 92 | 7 | 0 | 7 | 780 | 0 | 780 |
| 25 | កម្មន្តសាលផលិតផលពីលោហធាតុកែច្នៃលើកលែងម៉ាស៊ីន និងបរិក្ខារ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 2511 | កម្មន្តសាល ផលិតផលគ្រឿងគ្រោងពីលោហៈធាតុ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 25111 | កម្មន្តសាល ផលិតផលគ្រោងទ្វារគ្រោងបង្អួច | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 25920 | ប្រព្រឹត្តិកម្ម និងការពារលោហៈធាតុ ការក្រឡឹង | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 2599 | កម្មន្តសាល ផលិតផល ពីលោហៈធាតុកែច្នៃ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 25991 | កម្មន្តសាល ឧបករណ៍ប្រើប្រាស់ក្នុងផ្ទះ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 25999 | កម្មន្តសាល ផលិតផល ពីលោហៈធាតុកែច្នៃ ដទៃទៀតដែលពុំបានរាប់បញ្ចូល | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 31 | កម្មន្តសាលគ្រឿងសង្ហារឹម | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 3100 | កម្មន្តសាលគ្រឿងសង្ហារឹម | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 31001 | កម្មន្តសាល គ្រឿងសង្ហារឹមធ្វើពីឈើ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 31002 | កម្មន្តសាល គ្រឿងសង្ហារឹមធ្វើពីដែក | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| | សរុប | 40 | 2 | 0 | 15,137,144 | 2,842,765 | 3,833,274 | 2,154 | 2,536 | 39 | 1 | 40 | 74,726 | 0 | 74,726 |

ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១៦

ប្រធានមន្ទីរឧស្សាហកម្មនិងសិប្បកម្ម

ក្អួយ_ភូសល

ឧស្សាហកម្មតូចនិងមធ្យម

ថ្ងៃទី 30 ខែ វិច្ឆិកា ឆ្នាំ ២០១៦

ប្រធានការិយាល័យឧស្សាហកម្មនិងសិប្បកម្ម

ញ៉ាត..សម្រេច

# តារាងសរុបស្ថិតិតាមផ្នែក និងអនុផ្នែកប្រចាំ ឆ្នាំ ២០១៦

| លេខកូដ | ផ្នែក និង អនុផ្នែក | ចំនួនមូលដ្ឋាន | សហគ្រិនជាស្ត្រី | ដើមទុន(ដុល្លារអាមេរិក) | | ពលកម្ម | | ចំនួនមូលដ្ឋានចុះបញ្ជី | | | តម្លៃបរិមាណផលិតផល (លានរៀល) | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ទុនអចលក | ទុនសរុប | ស្រី | សរុប | ក្រសួង | មន្ទីរ | សរុប | លក់ក្នុងស្រុក | នាំចេញ | សរុប |
| 10 | កម្មន្តសាលផលិតផលម្ហូបអាហារ | 29 | 2 | 2,080,835 | 2,956,344 | 6 | 154 | 28 | 1 | 29 | 10,717 | 0 | 10,717 |
| 11 | កម្មន្តសាលភេសជ្ជៈ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 12 | កម្មន្តសាលផលិតផលថ្នាំជក់ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 13 | កម្មន្តសាលវាយនភណ្ឌ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 14 | កម្មន្តសាលសម្លៀកបំពាក់ | 2 | 0 | 112230 | 142230 | 2085 | 2280 | 2 | 0 | 2 | 63229 | 0 | 63229 |
| 15 | កម្មន្តសាលស្បែកនិងផលិតផលស្បែកដទៃទៀត | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 16 | កម្មន្តសាលឈើនិងផលិតផលពីឈើនិងឈើ<br>ស្នោលើកលែងតែគ្រឿងសង្ហារឹម កម្មន្តសាល | - | - | - | - | - | - | - | - | - | - | - | - |
| 17 | កម្មន្តសាលក្រដាសនិងផលិតផលក្រដាស | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 18 | ការបោះពុម្ពនិងការផលិតសារឡើងវិញនូវឯកសារ | - | - | - | - | - | - | - | - | - | - | - | - |
| 19 | កម្មន្តសាលធ្យូងថ្មនិងផលិតផលកាកសំណល់ | - | - | - | - | - | - | - | - | - | - | - | - |
| 20 | កម្មន្តសាលគីមី និងផលិតផលគីមី | 2 | 0 | 104700 | 104900 | 0 | 10 | 2 | 0 | 2 | 0 | 0 | 0 |
| 21 | កម្មន្តសាលឱសថសារធាតុគីមីសម្រាប់ព្យាបាលនិង | - | - | - | - | - | - | - | - | - | - | - | - |
| 22 | កម្មន្តសាល ផលិតផលពីកៅស៊ូនិងប្លាស្ទិក | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 23 | កម្មន្តសាល ផលិតផលពីរ៉ែអលោហៈដទៃទៀត | 7 | 0 | 545000 | 629800 | 63 | 92 | 7 | 0 | 7 | 780 | 0 | 780 |
| 24 | កម្មន្តសាលលោហៈធាតុមូលដ្ឋាន | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 25 | កម្មន្តសាលផលិតផលពីលោហធាតុកែច្នៃលើកលែងម៉ាស៊ីន | - | - | - | - | - | - | - | - | - | - | - | - |
| 26 | កម្មន្តសាលផលិតផលកុំព្យូទ័រ អេឡិចត្រូនិកនិងអុបទិក | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 27 | កម្មន្តសាលបរិក្ខារអគ្គិសនី | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
